## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះវិហារ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ..........១៦..........."ឆ"

ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

សំណុំរឿងព្រហ្មទណ្ឌលេខ ៣០៦

ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១

សំណុំរឿងស៊ើបសួរលេខ ១៧៦

ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១

សំណុំរឿងជំនុំជម្រះលេខ ១៤៥

ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះវិហារ

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២
វេលាម៉ោង ០៣ និង០០ នាទីរសៀល នៅសាលសវនាការសាធារណៈ
នៃសាលាដំបូងខេត្តព្រះវិហារ ដោយមានសមាសភាពជំនុំជម្រះ ដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោក ជាចៅក្រមប្រឹក្សា

-លោក ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

**ដើម្បីជំនុំជម្រះ** លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣០៦ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅ[redacted] ខេត្តតាកែវ មានទីលំនៅមុនពេលឃុំខ្លួននៅភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ពុយ (រ) ម្តាយឈ្មោះ [redacted] ជ្រី (រ) ប្រពន្ធឈ្មោះ [redacted] គន្ធា មានកូនចំនួន ០៥ នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ មាន។ (**ក្នុងឃុំ**)

២. ឈ្មោះ [redacted] **ស្រីសី** ភេទស្រី អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តតាកែវ មានទីលំនៅមុនពេលឃុំខ្លួននៅភូ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ កុង (ស) ម្តាយឈ្មោះ [redacted] សិត (រ) មេម៉ាយ មានកូនចំនួន ០២ នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (**ក្នុងឃុំ**)

ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុផល និងជនជាប់ចោទឈ្មោះ [redacted] **ស្រីសី**។

៣. ឈ្មោះ [redacted] **រ៉ាដា** ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តតាកែវ បច្ចុប្បន្នកំពុងជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១ (ម១) ឪពុកឈ្មោះ [redacted] ចែម (រ) ម្តាយឈ្មោះ [redacted] ប៉ិច (រ) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ មាន។ (**ក្នុងឃុំ**)

ដោយមានលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ាដា។



Scanned with CamScanner

ត្រូវជាប់ចោទពីបទ រក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមហាផល ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុកើតមានឡើងដូចតទៅ

កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១៥ និង២៤ នាទី ស្ថិតនៅភូមិមហាផល ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ កម្លាំងជំនាញការិយាល័យប្រឆាំងគ្រឿងញៀន បានធ្វើការចុះបង្ក្រាបករណីរក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ ក្នុងករណីចុះបង្ក្រាបខាងលើនេះ សមត្ថកិច្ចបានឆែកឆេរ និងរកឃើញនូវថ្នាំញៀនជាប្រភេទម្សៅក្រាមពណ៌សថ្លា ចំនួន ៦៨៦, ៧៥ ក្រាម។

-**បានឃើញ**: ដីកាបញ្ជូនលេខ ៩២/២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ របស់ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ។

-**បានឃើញ**: ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ៩៦៩ ដ.ស.ស/២១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រះវិហារ។

-**បានឃើញ**: ដីកាសន្និដ្ឋានស្ថាពរលេខៈ ៤២៤ ដ.ស.ព/២២ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តព្រះវិហារ។

-**បានឃើញ**: ដីកាដំណោះស្រាយលេខៈ ៩០៣/២២ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះវិហារ ។

-**បានឃើញ**: ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ ៣១២/២០២២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ ។

-**បានឃើញ**: ដីកាសម្រេចដាក់រឿងក្តីជំនុំជម្រះលេខៈ ២៦៩/២០២២ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] សុផល បានឆ្លើយនាពេលសវនាការថាៈ ខ្លួនរកស៊ីគ្រប់មុខ ដោយមុខរបរជាប់លាប់របស់ខ្លួនគឺបើកសិប្បកម្មឈើនៅខេត្តបាត់ដំបង។ នៅមុនពេលដែលសមត្ថកិច្ចឃាត់រូបខ្លួននោះ គឺខ្លួនបានធ្វើដំណើរពីខេត្តតាកែវមក ដោយជិះកាត់ខេត្តព្រះវិហារ តាមផ្លូវជាតិលេខ ៦២ ព្រោះដោយសារខ្លួនត្រូវចូលមកវាស់គ្រែនៅគោកមន ខេត្តឧត្តរមានជ័យឱ្យថៅកែខ្លួនឈ្មោះ [redacted] ស្រ៊ុន។ នៅពេលមកដល់ខេត្តព្រះវិហារ ដល់ចំណុចមុខលោកតាឪ មានបុរសមាឌធំសម្បុរខ្មៅ បានខលតាមទូរសព្ទមកខ្លួន និងបានយកកេសមួយមកឱ្យខ្លួនដាក់ផ្ញើតាមឡានរបស់ខ្លួនដើម្បីផ្ញើទៅខេត្តបាត់ដំបង ដោយយកទៅឱ្យគេនៅម្តុំព្រាបស។ ខ្លួនមិនធ្លាប់ស្គាល់អ្នកដែលយកអីវ៉ាន់មកផ្ញើតាមឡានខ្លួននោះទេ គឺខ្លួនបានលេខទូរសព្ទរបស់បុរសខាងលើពីមិត្តភក្តិរបស់ខ្លួនដែលមានផ្ទះនៅជិតកន្លែងខ្លួនធ្វើសិប្បកម្មនៅខេត្តបាត់ដំបង។ នៅពេលដែលនិយាយទូរសព្ទ និងលើកអីវ៉ាន់ដែលគេផ្ញើដាក់ចូលឡាននោះ ឈ្មោះ [redacted] ស្រីសី កំពុងតែសំងំគេងដោយសារនាងក្តៅខ្លួន (ព្រោះឡើងសុជន់) និងមិនបានដឹងរឿងដែលខ្លួននិយាយជាមួយនឹងអ្នកដែលផ្ញើអីវ៉ាន់នោះទេ។ នៅពេលដែលបានដាក់អីវ៉ាន់ចូលឡានហើយ ខ្លួនក៏បានបើកឡានទៅមុខបន្តទៀត មកដល់ចំណុចមហាផល ក៏ស្រាប់តែមានសមត្ថកិច្ចដែលកំពុងនៅគោលដៅត្រួតពិនិត្យសុវត្ថិភាពចរាចរណ៍ផ្លូវគោកបានឃាត់រថយន្តរបស់ខ្លួន ដោយសារតែខ្លួនបានបើករថយន្តដោយល្មើសនឹងល្បឿនដែលច្បាប់បានកំណត់។ បន្ទាប់មកសមត្ថកិច្ចបានធ្វើការសាកសួររកឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងរថយន្ត ហើយដោយសារតែខ្លួនមិនមានឯកសាររថយន្តគ្រប់គ្រាន់ និងដោយសារតែរថយន្តរបស់ខ្លួនមិនមានពន្ធទៀត ហើយដោយសារតែពេលនោះឈ្មោះ [redacted] ស្រីសី ក្តៅខ្លួនផង (សមត្ថកិច្ចសង្ស័យថាកើតកូវីត) ទើបសមត្ថ



Scanned with CamScanner

កិច្ចបានបញ្ជូនរថយន្តខ្លួន និងរូបខ្លួនទាំងពីរនាក់ទៅកាន់ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ ដើម្បីដោះស្រាយតាមនីតិវិធីច្បាប់ និងដាក់ឈ្មោះ [redacted] **ស្រីសី** ឱ្យនៅដាច់ដោយឡែក។ នៅពេលមកដល់ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ សមត្ថកិច្ចបានធ្វើការឆែកឆេររថយន្តរបស់ខ្លួន ទើបឃើញថានៅក្នុងកេសដែលគេផ្ញើឱ្យដឹកទៅខេត្តបាត់ដំបងនោះជាថ្នាំញៀន។ ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅដំណាក់កាលមុនៗថាឈ្មោះ **រ៉ាដា** ដែលនៅក្នុងមណ្ឌលអប់រំកែប្រែ (ម១) ជាអ្នកបញ្ជាឱ្យខ្លួនយកថ្នាំញៀនឱ្យគេនៅខេត្តបាត់ដំបងនោះ ជាចម្លើយដែលខ្លួនចេះតែឆ្លើយផ្ដេសផ្ដាសទេ ដោយហេតុថាសមត្ថកិច្ចបានឆែកទូរសព្ទរបស់ខ្លួន ហើយបានឃើញឈ្មោះនេះនៅក្នុងទូរសព្ទ ដោយសមត្ថកិច្ចចេះតែជំរិតសួរខ្លួនពេក និងដោយសារតែខ្លួនមិនសូវស្រួលខ្លួនផង មិនមានថ្នាំលេបផង ហើយសមត្ថកិច្ចបានសួរខ្លួនមកមួយយប់មួយថ្ងៃហើយ ទើបខ្លួនចេះតែឆ្លើយទៅថាឈ្មោះនេះជាមេគ្រឿងញៀននៅព្រៃស។ ខ្លួនសូមបដិសេធចោលនូវចម្លើយដែលបានឆ្លើយនៅដំណាក់កាលមុនៗ ពីព្រោះខ្លួនពិតជាមិនបានដឹងមែនថាអីវ៉ាន់ដែលខ្លួនដឹកឱ្យគេនោះជាថ្នាំញៀន។

- ជនជាប់ចោទឈ្មោះ [redacted] **ស្រីសី** បានឆ្លើយនាពេលសវនាការថា៖ ខ្លួនត្រូវជាស្រីកំណាន់របស់ឈ្មោះ [redacted] **សុផល** ដោយខ្លួនបានទាក់ទងគ្នាដោយលួចលាក់រយៈពេលជាង ១ ឆ្នាំមកហើយ។ នៅមុនថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួននោះ ខ្លួនបានសុំឈ្មោះ **សុផល** ដើម្បីជិះឡានទៅបាត់ដំបងជាមួយគ្នា ដោយសារខ្លួនត្រូវយកអីវ៉ាន់ (លេលាបខ្លួន) ទៅឱ្យគេនៅស្រុកសំឡូត ខេត្តបាត់ដំបង។ នៅថ្ងៃទីមិនចាំ ខែមិថុនា ឆ្នាំ២០២១ ម៉ោងប្រហែលជា ៥ ទៅ ៦ ល្ងាច ខ្លួន និងឈ្មោះ **សុផល** បានធ្វើដំណើរចេញពីខេត្តតាកែវ ប៉ុន្តែខ្លួនមិនដឹងថាឈ្មោះ **សុផល** ជិះតាមផ្លូវណាទេ ដឹងតែថាម៉ោងប្រហែលជា ១១ យប់ ខ្លួន និងឈ្មោះ **សុផល** ក៏បានមកដល់កន្លែងមួយដែលមានភ្នំច្រើន (តែមិនដឹងដល់ណាទេ) ដោយសារតែឈ្មោះ **សុផល** ឈឺភ្នែក មិនអាចបើកឡានបន្តទៅទៀតបាន ក៏បានសម្រាកនៅទីនោះទៅ។ លុះព្រឹកឡើង ម៉ោងប្រហែលជា ៥ ព្រឹក ក៏បានបន្តដំណើរបន្តទៀត និងបានមកដល់ខេត្តហើយ ខ្លួន និងឈ្មោះ **សុផល** ក៏បានចូលទៅសម្រាកក្នុងបន្ទប់ផ្ទះសំណាក់មួយនៅទីរួមខេត្តព្រះវិហារ (ដើម្បីរួមភេទជាមួយគ្នា) រហូតដល់ម៉ោងប្រហែលជា ១១ ថ្ងៃត្រង់ ក៏បានចេញពីផ្ទះសំណាក់ និងបានទៅរកហូបអី។ បន្ទាប់ពីហូបអាហារថ្ងៃត្រង់ហើយ ឈ្មោះ **សុផល** ក៏បានដូរកង់ឡាន និងបានបន្តដំណើរចេញមកទៀត។ ខ្លួនបានឮឈ្មោះ **សុផល** និយាយទូរសព្ទ ប៉ុន្តែមិនដឹងនិយាយពីអ្វីទេ ដោយសារពេលនោះខ្លួនបានសំងំគេងព្រោះមិនសូវស្រួលខ្លួន (ឡើងសុជន់) និងដឹងថាឈ្មោះ **សុផល** ឈប់ឡាន ដើម្បីឱ្យគេដាក់អីវ៉ាន់ចូលឡាន ប៉ុន្តែខ្លួនមិនបានដឹងច្បាស់ឡើយ ដោយសារពេលនោះខ្លួននៅក្នុងឡាន ហើយឈ្មោះ **សុផល** និងអ្នកផ្ញើអីវ៉ាន់និយាយគ្នានៅខាងក្រោយឡាន។ បន្ទាប់មក ក៏បានបន្តដំណើរទៅមុខបានបន្តិច ស្រាប់តែប៉ូលីសចរាចរណ៍បានឃាត់រថយន្តឱ្យឈប់ព្រោះដោយសារបើកលើសល្បឿនកំណត់។ ដោយហេតុថាពេលនោះ ខ្លួនឡើងកំដៅដល់លើសពី ៣៧ អង្សា ទើបសមត្ថកិច្ចបានបំបែកឱ្យខ្លួននៅផ្សេងពីឈ្មោះ **សុផល** និងអោយអង្គុយនៅកន្លែងត្រជាក់។ ខ្លួនមិនបានដឹងថាឈ្មោះ **សុផល** និយាយអ្វីខ្លះជាមួយនឹងសមត្ថកិច្ចឡើយ ដោយដឹងត្រឹមថាដោយសារមិនមានឯកសាររថយន្តគ្រប់ ទើបបានបញ្ជូនរូបខ្លួនទាំងពីរ និងរថយន្តទៅស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ។ នៅមុនពេលបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តព្រះវិហារនោះ សមត្ថកិច្ចមិនបានឆែករថយន្តឡើយ។ នៅពេលបញ្ជូនមកដល់ស្នងការដ្ឋាន ទើបឆែករថយន្ត និងឃើញមានថ្នាំញៀននៅក្នុងរថយន្តតែម្តង។ ខ្លួនសូមបដិសេធថា ខ្លួនពិតជាមិនបានដឹងឡើយថាក្នុងកេសដែលគេផ្ញើនោះមានថ្នាំញៀន ហើយខ្លួនក៏មិនបានដឹងថាឈ្មោះ [redacted] **សុផល** និយាយអ្វីខ្លះដែរជាមួយនឹងម្ចាស់អីវ៉ាន់ ដឹងត្រឹមឈ្មោះនេះនិយាយទូរសព្ទជាមួយគេ។

- ជនជាប់ចោទឈ្មោះ [redacted] **រ៉ាដា** បានឆ្លើយនាពេលសវនាការថា៖ ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ [redacted] **ស្រីសី** និងឈ្មោះ [redacted] **សុផល** ពីមុនមកឡើយ។ ហើយខ្លួនក៏មិនបានដឹងថាហេតុអ្វីបានជាឈ្មោះ [redacted] **សុផល** ឆ្លើយថាឈ្មោះ **រ៉ាដា** ជាអ្នកបញ្ជាតាមទូរសព្ទពីមណ្ឌលអប់រំកែប្រែទី១ (ម១) ឱ្យយកថ្នាំញៀនទៅឱ្យគេនៅខេត្តបាត់ដំបងដែរ

ពីព្រោះនៅក្នុងអំឡុងពេលនៃការជាប់ឃុំឃាំងក្នុងមណ្ឌលអប់រំកែប្រែទី១ (ម១) គឺមិនត្រូវបានអនុញ្ញាតឱ្យនិយាយ ឬ ប្រើប្រាស់ទូរសព្ទឡើយ។ ហើយនៅពេលបងប្អូនសាច់ញាតិចង់ជួប ទាល់តែមកជួបខ្លួនផ្ទាល់នៅមណ្ឌលអប់រំកែប្រែទី១ តែម្តង និងនៅពេលនិយាយគ្នាគឺស្ថិតនៅក្រោមការឃ្លាំមើលរបស់អនុរក្សពន្ធនាគារយ៉ាងតឹងរ៉ឹងបំផុត ដោយមានរនាំងនៅឃាំងចំកណ្ដាល។ ខ្លួនសូមបដិសេធថាខ្លួនមិនបានបញ្ជាឱ្យឈ្មោះ [redacted] **សុផល** យកថ្នាំញៀនទៅឱ្យគេនៅខេត្តបាត់ដំបងឡើយ ហើយខ្លួនក៏មិនធ្លាប់ស្គាល់ ឬ មានទំនាក់ទំនងជាមួយនឹងឈ្មោះខាងលើពីមុនមកឡើយ ហើយខ្លួនបានជាប់ពន្ធនាគាររយៈពេលជាង ០៤ ឆ្នាំមកហើយ តាំងពីឆ្នាំ ២០១៨ មកម្ល៉េះ។

- តុលាការបានធ្វើការសួរចម្លើយតទល់រវាងជនជាប់ចោទឈ្មោះ [redacted] **សុផល** និងជនជាប់ចោទឈ្មោះ [redacted] **រ៉ាដា** ដោយជនជាប់ចោទឈ្មោះ [redacted] **សុផល** បានឆ្លើយថា៖ ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ **រ៉ាដា** ដែលមានវត្តមាននាពេល សវនាការនេះពីមុនមកឡើយ ហើយចម្លើយដែលខ្លួនឆ្លើយថា ឈ្មោះ **រ៉ាដា** ដែលបច្ចុប្បន្នកំពុងជាប់ឃុំនៅព្រៃសជាអ្នកបញ្ជានោះ ជាចម្លើយដែលខ្លួនចេះតែឆ្លើយផ្ដេសផ្ដាសប៉ុណ្ណោះ ដោយសារតែសមត្ថកិច្ចបានជំរិតសួរឱ្យឆ្លើយពេក និងដោយសារតែខ្លួនមិនស្រួលខ្លួនផង ទើបចេះតែឆ្លើយឱ្យតែរួចៗទៅ។ ខ្លួនមិនបានឆ្លើយដើម្បីជួយឈ្មោះ **រ៉ាដា** នេះឡើយ ពីព្រោះឈ្មោះនេះក៏មិនបានត្រូវជាបងប្អូនសាច់ញាតិអ្វីជាមួយនឹងខ្លួន ហើយក៏គ្មានផលប្រយោជន៍អ្វីដើម្បីខ្លួនឆ្លើយជួយអ្នកនេះដែរ។

- ក្រឡាបញ្ជីអានកំណត់ហេតុទទួលស្គាល់សម្ភារៈ និងវត្ថុតាង ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ដែលក្នុងនោះរួមមាន៖ ម្សៅក្រាមពណ៌សថ្លា ជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន ទម្ងន់ ៦៨៦.៧៥ (ប្រាំមួយរយប៉ែតសិបប្រាំមួយកណ្តក់សញ្ញាចិតសិបប្រាំ) ក្រាម, រថយន្តម៉ាក HIGHLANDER ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ 2D-6840 ចំនួន ០១ គ្រឿង, ទូរសព្ទម៉ាក VIVO ពណ៌ផ្ទៃមេឃ ចំនួន ០១ គ្រឿង (ចាស់) និងម៉ាក HUAWEI ពណ៌មាស ចំនួន ០១ គ្រឿង (ចាស់), ប័ណ្ណបើកបរ ចំនួន ០១ សន្លឹក, ទូរសព្ទដៃ ចំនួន ០២ គ្រឿង, ប្រាក់រៀលចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំនួន ០១ សន្លឹក, ប័ណ្ណសម្គាល់យានយន្តចំនួន ៤ សន្លឹក។

- ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ ដែលក្នុងនោះរួមមាន៖ ម្សៅក្រាមពណ៌សថ្លា ទម្ងន់ ៦៨៦.៧៥ (ប្រាំមួយរយប៉ែតសិបប្រាំមួយកណ្តក់សញ្ញាចិតសិបប្រាំ) ក្រាម, ទូរសព្ទម៉ាក VIVO ពណ៌ផ្ទៃមេឃ ចំនួន ០១ គ្រឿង (ចាស់) និងម៉ាក HUAWEI ពណ៌មាស ចំនួន ០១ គ្រឿង (ចាស់), ប្រាក់រៀលចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] **ស្រីសី** ចំនួន ០១ សន្លឹក, ប័ណ្ណបើកបរឈ្មោះ [redacted] **សុផល** ចំនួន ០១ សន្លឹក, កាបូបពណ៌ខ្មៅចំនួន ០១, រូបថតចំនួន ០១ សន្លឹក, ប្រអប់ក្រដាសពណ៌ប្រាក់ចំនួន ០១ និងប្រអប់ជ័រតូច ពណ៌សថ្លាចំនួន ០១។

- ក្រឡាបញ្ជីអានលទ្ធផលកោសលវិច្ច័យគ្រឿងញៀនលេខ: **៣៣៩៣៩/២១** ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយបានធ្វើសេចក្តីសន្និដ្ឋានថា៖ សំណាកគ្រឿងញៀនដែលបានដកហូតពីឈ្មោះ [redacted] **សុផល** ជាប្រភេទម្សៅថ្លា ពណ៌ស មានវិជ្ជមានវត្តមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** ដែលមានកម្រិតភាពសុទ្ធ **៧៦.៣៤ % (ចិតសិបប្រាំមួយកណ្តក់សញ្ញាសាមសិបបួនភាគរយ)** នៃទម្ងន់សរុបស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចដែលមានចែងក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- ក្រឡាបញ្ជីអានលិខិតបញ្ជាក់ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ របស់មេភូមិស្មោង ដែលបញ្ជាក់ថាឈ្មោះ [redacted] **សុផល** ភេទប្រុស អាយុ ៤០ឆ្នាំ មានទីលំនៅនៅភូមិស្មោង ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ មានកូនចំនួន ០៥ នាក់ ដោយកូនទី០៣ មានឈ្មោះ [redacted] **ពេជ្រទ័រ** ជាក្មេងដែលមានសតិមិនល្អ ហើយឈ្មោះ [redacted] **គន្ធា** ជាប្រពន្ធត្រូវមើលថែកូនទាំង ០៥ នាក់តែម្នាក់ឯង។

- ក្រឡាបញ្ជីអានវេជ្ជបញ្ជា ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ដែលអ្នកជំងឺឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ៣៩ឆ្នាំ ដោយពេតនិច្ឆ័យបញ្ជាក់ថាអ្នកជំងឺខាងលើមានជំងឺលោកទងសួត (បកប្រែពីភាសាបារាំង)។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

- **តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ** ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងបីនាក់ខាងលើរួចមក ឃើញថានៅថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ស្រីសី នោះ អ្នកទាំងពីរបានធ្វើដំណើរពីខេត្តតាកែវ ទៅខេត្តបាត់ដំបង ដោយបានជិះកាត់ខេត្តព្រះវិហារតាមផ្លូវជាតិលេខ ៦២។ បន្ទាប់ពីបានទទួលបញ្ញើទៅគោកមនហើយ ក៏ជាប់នឹងបារ៉ាស់របស់ប៉ូលីសចរាចរណ៍ដោយសារតែបើកលើសល្បឿន និងការរឹតបន្តឹងបញ្ហាកូវីត ហើយដោយសារតែឈ្មោះ [redacted] ស្រីសី បានឡើងកម្តៅ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនឱ្យនៅវាស់កម្តៅ។ បន្ទាប់ពីបានសាកសួររកឯកសារទាក់ទងនឹងរថយន្ត ឃើញថាមិនមានឯកសារគ្រប់ និងដោយសារតែរថយន្តមិនមានពន្ធផង ទើបបាននាំខ្លួនជនជាប់ចោទមកកាន់ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ។ នៅពេលមកដល់ស្នងការដ្ឋាន ក៏បានឆែកឆេររថយន្ត និងរកឃើញមានថ្នាំញៀននៅក្នុងរថយន្តដែលមានទម្ងន់ ៦០០ ក្រាមជាង។ នៅពេលដែលមានការស្តាប់ចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងចៅក្រមស៊ើបសួរ ឈ្មោះ **សុផល** បានឆ្លើយថាមានគេបញ្ជាពីពន្ធនាគារព្រៃសមកឱ្យយកថ្នាំញៀនឱ្យគេ ហើយចំណុចដែលគួរឱ្យកត់សម្គាល់មួយទៀតគឺឈ្មោះ **សុផល** បានឆ្លើយពីមុនថាខ្លួនមិនមានមុខរបរពិតប្រាកដទេ ប៉ុន្តែក្រោយមកថាខ្លួនធ្វើសិប្បកម្ម និងបើកឡានតាក់ស៊ីដឹកអីវ៉ាន់ ដែលចម្លើយនេះជាចម្លើយដែលចេះតែឆ្លើយតាមការនឹកឃើញ ហេតុនេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់លើឈ្មោះ [redacted] សុផល និងប្តឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទខាងលើទៅតាមច្បាប់។

ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] ស្រីសី ជាស្រីស្នេហ៍របស់ឈ្មោះ [redacted] សុផល វិញ តំណាងអយ្យការយល់ថា ជនជាប់ចោទខាងលើអាចនឹងមិនដឹងអំពីការទទួលដឹកជញ្ជូនថ្នាំញៀនខាងលើពិតមែន ហេតុនេះតំណាងអយ្យការទុកសិទ្ធិជូនក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅតាមច្បាប់។

ចំពោះជនជាប់ចោទឈ្មោះ [redacted]រ៉ាដា វិញ តំណាងអយ្យការយល់ឃើញថាមិនមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទខាងលើឡើយ ដោយហេតុថាឈ្មោះ [redacted] សុផល ក៏បានឆ្លើយបញ្ជាក់ដែរថាមិនដែលស្គាល់ឈ្មោះ **រ៉ាដា** នេះទេ ហើយនៅក្នុងពន្ធនាគារព្រៃសក៏មិនអនុញ្ញាតឱ្យមានការនិយាយ ឬ ប្រើប្រាស់ទូរសព្ទដែរ ហេតុនេះការបញ្ជាឱ្យមានការដឹកជញ្ជូនថ្នាំញៀន គឺមិនអាចកើតឡើងទៅបានឡើយ ហេតុនេះតំណាងអយ្យការប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យជនជាប់ចោទខាងលើរួចខ្លួនពីបទចោទប្រកាន់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុផល និងឈ្មោះ [redacted] ស្រីសី បានធ្វើសេចក្តីសន្និដ្ឋានការពារដូចតទៅៈ មិនបដិសេធចំពោះការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការទេ ប៉ុន្តែសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅលើថ្នាំញៀនជាង ៦០០ ក្រាម ដែលដកហូតបានពីរថយន្តកូនក្តីរបស់ខ្លួននោះ គឺកូនក្តីខ្លួនបានឆ្លើយបញ្ជាក់ជូនអង្គសវនាការហើយថាជាអីវ៉ាន់ដែលខ្លួនទទួលដឹកឱ្យគេទៅ បាត់ដំបង និងទទួលបានសោរ៉ាចំនួន ៥ ដុល្លារ។ ដោយឡែកឈ្មោះ [redacted] ស្រីសី គឺមិនបានដឹងរឿងអ្វីទាំងអស់ គ្រាន់តែរួមដំណើរជាមួយនឹងឈ្មោះ [redacted] សុផល ហើយឈ្មោះ **សុផល** ក៏មិនបានដឹងថាកេសអីវ៉ាន់នោះជាថ្នាំញៀនដែរ ទាល់តែសមត្ថកិច្ចឆែកឆេរទើបដឹងថាជាថ្នាំញៀន។ ផ្អែកតាមចម្លើយរបស់កូនក្តីខ្លួន ឃើញថាមានវិមតិសង្ស័យ ហើយគ្មានភស្តុតាងដាក់បន្ទុកផ្សេងទៀតក្រៅពីថ្នាំញៀនដែលដកហូតបានពីរថយន្តរបស់ឈ្មោះ [redacted] សុផល ឡើយ។ ហេតុនេះសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចឱ្យកូនក្តីរបស់ខ្លួនទាំងពីររូប រួចខ្លួនពីបទចោទប្រកាន់ខាងលើ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ាដា បានធ្វើសេចក្តីសន្និដ្ឋានការពារដូចតទៅ៖ ជនជាប់ចោទឈ្មោះ [redacted] សុផល បានឆ្លើយបញ្ជាក់ជូនអង្គសវនាការរួចហើយ ថាចម្លើយដែលឆ្លើយថាឈ្មោះ រ៉ាដា ជាអ្នកបញ្ជាឱ្យដឹកថ្នាំញៀនយកទៅឱ្យគេនៅខេត្តបាត់ដំបងនោះ ជាចម្លើយដែលចេះតែឆ្លើយ ហើយនាពេលសវនាការឈ្មោះខាងលើក៏បានបញ្ជាក់ថាមិនធ្លាប់ស្គាល់ឈ្មោះនេះដែរ ហើយកូនក្តីរបស់ខ្លួនក៏បានឆ្លើយបដិសេធនៅគ្រប់ដំណាក់កាលថាមិនធ្លាប់ស្គាល់ឈ្មោះ [redacted] សុផល ហើយក៏មិនបានបញ្ជាឈ្មោះនេះឱ្យដឹកថ្នាំញៀនឱ្យគេដែរ ឃើញថាមានវិមតិសង្ស័យ ហើយមិនបំពេញលក្ខខណ្ឌលើសពីវិមតិសង្ស័យដែរ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចឱ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទប្រកាន់។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

- ជនជាប់ចោទឈ្មោះ [redacted] សុផល បាននិយាយសម្តីចុងក្រោយថា៖ សូមឱ្យតុលាការមេត្តាសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ផង ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ហើយម្យ៉ាងវិញទៀតខ្លួនក៏កំពុងតែមានជំងឺប្រចាំកាយផងដែរ ដោយមានជំងឺរលាកទងសួតរ៉ាំរ៉ៃ ដែលត្រូវទទួលការព្យាបាលជិតដល់ ប៉ុន្តែតាំងពីជាប់ឃុំមក សភាពជំងឺរបស់ខ្លួនកាន់តែធុនធាបទៅដោយពេលខ្លះស្ទះដង្ហើម ហើយម្យ៉ាងវិញទៀតជីវភាពគ្រួសាររបស់ខ្លួនក៏មានភាពលំបាកផងដែរក្រោយពេលខ្លួនជាប់ពន្ធនាគារមួយឆ្នាំជាងនេះមក ពីព្រោះប្រពន្ធខ្លួនមិនមានមុខរបរចិញ្ចឹមកូនឡើយ ហើយខ្លួនក៏មានកូនក្នុងបន្ទុកច្រើនដែលមានចំនួនរហូតដល់ទៅ ០៥ នាក់ និងកូនទី៣របស់ខ្លួននេះជាក្មេងដែលមានបញ្ហាស្មារតី (សតិមិនគ្រប់) ថែមទៀតផង។

- ជនជាប់ចោទឈ្មោះ [redacted] ស្រីសី បាននិយាយសម្តីចុងក្រោយថា៖ សូមឱ្យតុលាការមេត្តាសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ផង ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ហើយម្យ៉ាងវិញទៀតខ្លួនមានកូនតូចដែលមិនមានអ្នកមើលថែឡើយ ត្រូវការខ្លួនមើលថែដោយសារម្តាយរបស់ខ្លួនចាស់ជរាហើយ។

- ជនជាប់ចោទឈ្មោះ [redacted] រ៉ាដា បាននិយាយសម្តីចុងក្រោយថា៖ សូមឱ្យតុលាការមេត្តាសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ផង ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីសី
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ាដា
- ក្រោយពីបានស្តាប់ចម្លើយតទល់រវាងជនជាប់ចោទឈ្មោះ [redacted] សុផល និងជនជាប់ចោទឈ្មោះ [redacted] រ៉ាដា
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ហួយ សុផល និងជនជាប់ចោទឈ្មោះ [redacted] ស្រីសី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ាដា
- ក្រោយពីបានស្តាប់សំណូមពររបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា
- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. ផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខៈ ៣៣៩៣៩/២១ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានធ្វើសេចក្តីសន្និដ្ឋានថា៖ សំណាកគ្រឿងញៀនជាប្រភេទម្សៅថ្លាពណ៌ស មានវិជ្ជមានវត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៦.៣៤% (ចិតសិប



Scanned with CamScanner

ប្រាំមួយកណ្ដក់សញ្ញាសាមសិបបួនភាគរយ) នៃទម្ងន់សរុប ស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចដែលមានចែងក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។ ដោយថ្នាំញៀនដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] **សុផល** រួមមាន ប្រភេទម្សៅក្រាមពណ៌សថ្លាប្រភេទមេតំហ្វេតាមីន (ICE) មានទម្ងន់សរុប **៦៨៦.៧៥(ប្រាំមួយរយប៉ែតសិបប្រាំមួយកណ្ដក់សញ្ញាចិតសិបប្រាំ) ក្រាម** ហេតុនេះបរិមាណភាពសុទ្ធនៃថ្នាំញៀនសរុបស្មើនឹង ៦៨៦.៧៥ គុណនឹង ៧៦.៣៤ ចែកនឹង ១០០ ស្មើ ៥២៤.២៦ (ប្រាំរយម្ភៃបួនកណ្ដក់សញ្ញាម្ភៃប្រាំមួយ) ក្រាម។

២. ផ្អែកតាមចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ដែលបានឆ្លើយថាខ្លួនមិនបានដឹងឡើយថាអីវ៉ាន់ដែលគេផ្ញើឱ្យខ្លួនជួយដឹកទៅឱ្យគេនៅខេត្តបាត់ដំបងជាថ្នាំញៀន ទាល់តែសមត្ថកិច្ចឃាត់រថយន្ត និងបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តព្រះវិហារទើបដឹងថាជាថ្នាំញៀន ឃើញថាចម្លើយបដិសេធនេះមិនមានលក្ខណៈសមហេតុផលដែលអាចឱ្យតុលាការជឿជាក់បានថាជនជាប់ចោទខាងលើមិនបានប្រព្រឹត្តអំពើរក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនឡើយ ដោយហេតុថាចម្លើយរបស់ជនជាប់ចោទមានការប្រែប្រួលដោយមិនមានលក្ខណៈសមហេតុផល ដោយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងដំណាក់ចៅក្រមស៊ើបសួរ ជនជាប់ចោទខាងលើសុទ្ធតែបានឆ្លើយថាខ្លួនពិតជាបានដឹកថ្នាំញៀនឱ្យគេ ដោយត្រូវមកទទួលនៅខេត្តព្រះវិហារ និងដឹកចេញទៅឱ្យគេនៅខេត្តបាត់ដំបង ដោយស្ថិតនៅក្រោមការបង្គាប់បញ្ជាចេញពីមណ្ឌលអប់រំកែប្រែទី១ (ម១)។

៣. ផ្អែកតាមចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] **ស្រីសី** មានភាពស៊ីសង្វាក់គ្នានឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ដែលអាចឱ្យតុលាការជឿជាក់បានថាជនជាប់ចោទខាងលើមិនបានប្រព្រឹត្តអំពើរក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនឡើយ ដោយហេតុថានៅពេលដែលឈ្មោះ [redacted] **សុផល** និយាយទូរសព្ទឆ្លងឆ្លើយជាមួយនឹងអ្នកផ្ញើអីវ៉ាន់ និងដាក់អីវ៉ាន់ចូលរថយន្តនោះ ឈ្មោះ [redacted] **ស្រីសី** កំពុងតែសំងំគេងដោយសារតែមិនសូវស្រួលខ្លួន ដោយមិនបានដឹងថាឈ្មោះ [redacted] **សុផល** ដឹកថ្នាំញៀនទៅឱ្យគេនៅខេត្តបាត់ដំបងឡើយ។

៤. ផ្អែកតាមចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] **វ៉ាដា** មានភាពស៊ីសង្វាក់គ្នានឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ដែលអាចឱ្យតុលាការជឿជាក់បានថាជនជាប់ចោទខាងលើមិនបានប្រព្រឹត្តអំពើរក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនឡើយ ដោយហេតុថាឈ្មោះ [redacted] **សុផល** បានឆ្លើយបញ្ជាក់ហើយថាខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ **វ៉ាដា** នេះឡើយ ហើយចម្លើយដែលឆ្លើយនៅដំណាក់កាលមុនជាចម្លើយដែលខ្លួនចេះតែឆ្លើយផ្ដេសផ្ដាសដោយសារតែសមត្ថកិច្ចជំរិតសួរខ្លួនពេក ហើយម្យ៉ាងវិញទៀតជនជាប់ឃុំនៅក្នុងមណ្ឌលអប់រំកែប្រែទី១ (ម១) គឺមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ទូរសព្ទឡើយ ហេតុនេះលទ្ធភាពនៃការបញ្ជាឱ្យដឹកថ្នាំញៀនឱ្យគេគឺមិនអាចកើតមានឡើយ។

៥. អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផល** ខាងលើ ស្ថិតនៅក្នុងនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយបានប្រព្រឹត្តបទល្មើសដោយមានចេតនាយល់ដឹងអំពីអំពើ និងព្យសនកម្មដែលបានកើតចេញពីអំពើរបស់ខ្លួន។

៦. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ៖ ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទទាំងបីនាក់ខាងលើរួចមក ឃើញថានៅថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **សុផល** និងឈ្មោះ [redacted] **ស្រីសី** នោះ អ្នកទាំងពីរបានធ្វើដំណើរពីខេត្តតាកែវ ទៅខេត្តបាត់ដំបង ដោយបានជិះកាត់ខេត្តព្រះវិហារតាមផ្លូវជាតិលេខ៦២។ បន្ទាប់ពីបានទទួលបញ្ញើទៅគោកមនហើយ ក៏ជាប់នឹងប៉ាស់របស់ប៉ូលីសចរាចរណ៍ដោយសារតែបើកលើសល្បឿន និងការរឹតបន្តឹងបញ្ហាកូវីត ហើយដោយសារតែឈ្មោះ [redacted] **ស្រីសី** បានឡើងកម្ដៅ ក៏ត្រូវបាន



Scanned with CamScanner

សមត្ថកិច្ចឃាត់ខ្លួនឱ្យនៅរង់ចាំសិនភ្លាម។ បន្ទាប់ពីបានសាកសួរកងកសារទាក់ទងនឹងរថយន្ត ឃើញថាមិនមានឯកសារគ្រប់គ្រាន់ និងដោយសារតែរថយន្តមិនមានពន្ធផង ទើបបាននាំខ្លួនជនជាប់ចោទមកកាន់ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ។ នៅពេលមកដល់ស្នងការដ្ឋាន ក៏បានឆែកឆេររថយន្ត និងរកឃើញមានថ្នាំញៀននៅក្នុងរថយន្ត ដែលមានទម្ងន់ ៦០០ ក្រាមជាង។ នៅពេលដែលមានការស្ដាប់ចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងចៅក្រមស៊ើបសួរ ឈ្មោះ **សុផល** បានឆ្លើយថាមានគេបញ្ជាពីពន្ធនាគារព្រៃសមកឱ្យយកថ្នាំញៀនឱ្យគេ ហើយចំណុចដែលគួរឱ្យកត់សម្គាល់មួយទៀតគឺឈ្មោះ **សុផល** បានឆ្លើយពីមុនថាខ្លួនមិនមានមុខរបរពិតប្រាកដទេ ប៉ុន្តែក្រោយមកថាខ្លួនធ្វើសិប្បកម្ម និងបើកឡានតាក់ស៊ីដឹកអីវ៉ាន់ ដែលចម្លើយនេះជាចម្លើយដែលចេះតែឆ្លើយតាមការនឹកឃើញ ហេតុនេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់លើឈ្មោះ [redacted] **សុផល** និងប្ដឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្ដន្ទាទោសជនជាប់ចោទខាងលើទៅតាមច្បាប់។ ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] **ស្រីសី** ជាស្រីស្នេហ៍របស់ឈ្មោះ [redacted] **សុផល** វិញ តំណាងអយ្យការយល់ថា ជនជាប់ចោទខាងលើអាចនឹងមិនដឹងអំពីការទទួលដឹកជញ្ជូនថ្នាំញៀនខាងលើពិតមែន ហេតុនេះតំណាងអយ្យការទុកសិទ្ធិជូនក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅតាមច្បាប់។ ចំពោះជនជាប់ចោទឈ្មោះ [redacted] **រ៉ាដា** វិញ តំណាងអយ្យការយល់ឃើញថាមិនមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទខាងលើឡើយ ដោយហេតុថាឈ្មោះ [redacted] **សុផល** ក៏បានឆ្លើយបញ្ជាក់ដែរថាមិនដែលស្គាល់ឈ្មោះ **រ៉ាដា** នេះទេ ហើយនៅក្នុងពន្ធនាគារព្រៃសក៏មិនអនុញ្ញាតឱ្យមានការនិយាយ ឬ ប្រើប្រាស់ទូរសព្ទដែរ ហេតុនេះការបញ្ជាឱ្យមានការដឹកជញ្ជូនថ្នាំញៀន គឺមិនអាចកើតឡើងទៅបានឡើយ ហេតុនេះតំណាងអយ្យការប្ដឹងសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យជនជាប់ចោទខាងលើរួចខ្លួនពីបទចោទប្រកាន់។ យល់ឃើញថា ការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាបាន។

៧. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** និងឈ្មោះ [redacted] **ស្រីសី** បានធ្វើសេចក្ដីសន្និដ្ឋានការពារ មិនបដិសេធចំពោះការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការទេ ប៉ុន្តែសូមឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅលើថ្នាំញៀនជាង ៦០០ ក្រាម ដែលដកហូតបានពីរថយន្តកូនក្ដីរបស់ខ្លួននោះ គឺកូនក្ដីខ្លួនបានឆ្លើយបញ្ជាក់ជូនអង្គសវនាការហើយថាជាអីវ៉ាន់ដែលខ្លួនទទួលដឹកឱ្យគេទៅបាត់ដំបង និងទទួលបានសេវាចំនួន ៥ ដុល្លារ។ ដោយឡែកឈ្មោះ [redacted] **ស្រីសី** គឺមិនបានដឹងរឿងអ្វីទាំងអស់ គ្រាន់តែរួមដំណើរជាមួយនឹងឈ្មោះ [redacted] **សុផល** ហើយឈ្មោះ [redacted] **សុផល** ក៏មិនបានដឹងថាកេសអីវ៉ាន់នោះជាថ្នាំញៀនដែរ ទាល់តែសមត្ថកិច្ចឆែកឆេរទើបដឹងថាជាថ្នាំញៀន។ ផ្អែកតាមចម្លើយរបស់កូនក្ដីខ្លួន ឃើញថាមានវិមតិសង្ស័យ ហើយគ្មានភស្តុតាងដាក់បន្ទុកផ្សេងទៀតក្រៅពីថ្នាំញៀនដែលដកហូតបានពីរថយន្តរបស់ឈ្មោះ [redacted] **សុផល** ឡើយ។ ហេតុនេះសូមឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចឱ្យកូនក្ដីរបស់ខ្លួនទាំងពីររូបរួចខ្លួនពីបទចោទប្រកាន់ខាងលើ។ ការធ្វើសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** ដែលបានស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យជនជាប់ឈ្មោះ [redacted] **សុផល** រួចខ្លួនពីបទចោទប្រកាន់ដោយសំអាងលើមូលហេតុដែលជនជាប់ចោទខាងលើមិនបានដឹង គ្រាន់តែដឹកអីវ៉ាន់ឱ្យគេដើម្បីយកថ្លៃសេវាដឹកជញ្ជូនចំនួន ៥ ដុល្លារនោះ យល់ឃើញថាមិនមានលក្ខណៈត្រឹមត្រូវដែលអាចឱ្យតុលាការលើកយកមកពិចារណាបានឡើយ។ ដោយឡែក ចំពោះការធ្វើសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សុផល** ដែលបានស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យជនជាប់ឈ្មោះ [redacted] **ស្រីសី** រួចខ្លួនពីបទចោទប្រកាន់ដោយសំអាងលើមូលហេតុដែលជនជាប់ចោទខាងលើមិនបានដឹង គ្រាន់តែរួមដំណើរជាមួយនឹងឈ្មោះ [redacted] **សុផល** យល់ឃើញថាមានលក្ខណៈត្រឹមត្រូវដែលអាចឱ្យតុលាការលើកយកមកពិចារណាបាន។

៨. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ាដា បានធ្វើសេចក្ដីសន្និដ្ឋានការពារៈ ជនជាប់ចោទឈ្មោះ [redacted] សុផល បានឆ្លើយបញ្ជាក់ជូនអង្គសវនាការរួចហើយ ថាចម្លើយដែលឆ្លើយថាឈ្មោះ រ៉ាដា ជាអ្នកបញ្ជាឱ្យដឹកថ្នាំញៀនយកទៅឱ្យគេនៅខេត្តបាត់ដំបងនោះ ជាចម្លើយដែលចេះតែឆ្លើយ ហើយនាពេលសវនាការឈ្មោះខាងលើក៏បានបញ្ជាក់ថាមិនធ្លាប់ស្គាល់ឈ្មោះនេះដែរ ហើយកូនក្ដីរបស់ខ្លួនក៏បានឆ្លើយបដិសេធនៅគ្រប់ដំណាក់កាលថាមិនធ្លាប់ស្គាល់ឈ្មោះ [redacted] សុផល ហើយក៏មិនបានបញ្ជាឈ្មោះនេះឱ្យដឹកថ្នាំញៀនឱ្យគេដែរ ឃើញថាមានវិមតិសង្ស័យ ហើយមិនបំពេញលក្ខខណ្ឌលើសពីវិមតិសង្ស័យដែរ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចឱ្យកូនក្ដីខ្លួនរួចខ្លួនពីបទចោទប្រកាន់។ ឃើញថា ការធ្វើសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ាដា មានលក្ខណៈត្រឹមត្រូវដែលអាចឱ្យតុលាការលើកយកមកពិចារណាបាន។

៩. ជនជាប់ចោទឈ្មោះ [redacted] ស្រីសី និងជនជាប់ចោទឈ្មោះ [redacted] រ៉ាដា បានសំណូមពរដល់តុលាការៈ សូមឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ផង ដោយហេតុថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ មានលក្ខណៈសមហេតុផលអាចឱ្យតុលាការលើកយកមកពិចារណាបាន។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] សុផល បានសំណូមពរដល់តុលាការៈ សូមឱ្យតុលាការសម្រេចឱ្យរួចខ្លួនផុតពីការចោទប្រកាន់ផង ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ មិនមានលក្ខណៈសមហេតុផលដែលអាចឱ្យតុលាការលើកយកមកពិចារណាបានឡើយ ប៉ុន្តែតុលាការអាចនឹងពិចារណាពីការផ្ដន្ទាទោសក្នុងកម្រិតអប្បបរមា ដោយពិចារណាលើស្ថានភាពសុខភាព បន្ទុកគ្រួសារ និងស្ថានភាពផ្សេងៗទៀតរបស់ជនជាប់ចោទ។

១០. គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស្រីសី និងជនជាប់ចោទឈ្មោះ [redacted] រ៉ាដា ពីបទ **រក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមហាផល ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៧ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

១១. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុផល ពីបទ **រក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមហាផល ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៧ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

១២. គប្បីប្រកាសទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] **សុផល** ក្នុងកម្រិតអប្បបរមាដោយគិតគូរពិចារណាអំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ គឺជនជាប់ចោទមានជំងឺរលាកទងសួត ដែលមានអាការៈស្ទះពិបាកដកដង្ហើមដែលទាមទារការព្យាបាលដិតដល់ ហើយម្យ៉ាងវិញទៀតទាក់ទងនឹងស្ថានភាពនៃបន្ទុកគ្រួសារវិញ ឃើញថាក្រោយពីជនជាប់ចោទបានជាប់ពន្ធនាគាររយៈពេលជាង ០១ ឆ្នាំមកនេះ ស្ថានភាពជីវភាពគ្រួសារគឺមានការលំបាកខ្លាំង ដោយសារតែប្រពន្ធជនជាប់ចោទមិនមានមុខរបរ ហើយមានកូនក្នុងបន្ទុកច្រើន រហូតដល់ទៅ ០៥ នាក់ ហើយកូនទី៣ទៀតសោតជាក្មេងដែលមានបញ្ហាផ្នែកស្មារតី ដែលត្រូវស្ថិតក្រោមការមើលថែរបស់ប្រពន្ធជនជាប់ចោទទាំងអស់។

១៣. វត្ថុតាងរួមមានៈ ម្សៅក្រាមពណ៌សថ្លា ជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន ទម្ងន់ ៦៨៦.៧៥ (ប្រាំមួយរយប៉ែតសិបប្រាំមួយកណ្ដាក់សញ្ញាចិតសិបប្រាំ) ក្រាម, រថយន្តម៉ាក HIGHLANDER ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ 2D-6840 ចំនួន ០១ គ្រឿង, ទូរសព្ទម៉ាក VIVO ពណ៌ផ្ទៃមេឃ ចំនួន ០១ គ្រឿង (ចាស់) និងម៉ាក HUAWEI ពណ៌មាស ចំនួន ០១ គ្រឿង (ចាស់), ប្រាក់រៀលចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល, កាបូបពណ៌ខ្មៅចំនួន ០១, រូបថតចំនួន ០១ សន្លឹក, ប្រអប់ក្រដាសពណ៌ប្រាក់ចំនួន ០១ និងប្រអប់ជ័រតូច ពណ៌សថ្លាចំនួន ០១ គប្បីសម្រេចរឹបអូស តាមបញ្ញត្តិមាត្រា **៩៣** និងមាត្រា **៩៤** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។ ចំពោះអត្ត



Scanned with CamScanner

សញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] ស្រីសី ចំនួន ០១ សន្លឹក, ប័ណ្ណបើកបរឈ្មោះ [redacted] សុផល ចំនួន០១ សន្លឹក និងប័ណ្ណសម្គាល់យានយន្តចំនួន ០៤ សន្លឹក មិនមែនជាវត្ថុតាងនៃបទល្មើស គប្បីសម្រេចប្រគល់ឱ្យទៅម្ចាស់ដើមវិញ។

## ហេតុដូច្នេះសម្រេច

**១. ឱ្យរួចខ្លួនពីបទចោទ ៖**

១.១ ជនជាប់ចោទឈ្មោ[redacted] រ៉ាដា ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ (សាវតារជាតិខាងលើ)

១.២ ជនជាប់ចោទឈ្មោះ [redacted] **ស្រីសី ភេទស្រី អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ** (សាវតារជាតិខាងលើ)

ពីបទ **រក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមហាផល ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៧ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២. ផ្តន្ទាទោស ៖**

ជនជាប់ចោទឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ (សាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល** ពីបទ **រក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមហាផល ឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៧ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៣. រឹបអូស** វត្ថុតាងរួមមាន៖ ម្សៅក្រាមពណ៌សថ្លា ជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន ទម្ងន់ ៦៨៦.៧៥ (ប្រាំមួយរយប៉ែតសិបប្រាំមួយកណ្តាក់សញ្ញាចិតសិបប្រាំ) ក្រាម, រថយន្តម៉ាក HIGHLANDER ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ 2D-6840 ចំនួន ០១ គ្រឿង, ទូរសព្ទម៉ាក VIVO ពណ៌ផ្ទៃមេឃ ចំនួន ០១ គ្រឿង (ចាស់) និងម៉ាក HUAWEI ពណ៌មាស ចំនួន ០១ គ្រឿង (ចាស់), ប្រាក់រៀលចំនួន ៥០០,០០០ (ហាសិបម៉ឺន) រៀល, កាបូបពណ៌ខ្មៅចំនួន ០១, រូបថតចំនួន ០១ សន្លឹក, ប្រអប់ក្រដាសពណ៌ប្រាក់ចំនួន ០១ និងប្រអប់ជ័រតូច ពណ៌សថ្លាចំនួន ០១។

**៤. ប្រគល់ឱ្យម្ចាស់ដើមវិញ៖** អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] **ស្រីសី** ចំនួន ០១ សន្លឹក, ប័ណ្ណបើកបរឈ្មោះ [redacted] សុផល ចំនួន០១សន្លឹក និងប័ណ្ណសម្គាល់យានយន្តចំនួន ០៤ សន្លឹក។

៥. សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា-[redacted] | ហត្ថលេខា និងត្រា-[redacted] | ហត្ថលេខា និងត្រា-[redacted] | ហត្ថលេខា និងត្រា-[redacted] |

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ២ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ខេត្តព្រះវិហារ, ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner